# ឱ !ខ្ញុំសង្ឃឹមថាចៅស្រីរបស់ខ្ញុំនឹងយល់អំពីសមាគមសង្គ្រោះ

*ដោយ ជូលី ប៊ី បេក*
*ប្រធានសមាគមន៍សង្គ្រោះទូទៅ*

វាជាឯកសិទ្ធិមួយ ដើម្បីថ្លែងទៅកាន់អ្នកនៅឯការប្រជុំដ៏ជាប្រវត្តិសាស្រ្តនេះ ។ វាជាពរជ័យមួយសម្រាប់យើង ក្នុងការមកជួបជុំគ្នា ។ អំឡុងពេលការបម្រើរបស់ខ្ញុំ ជាប្រធានសមាគមន៍សង្គ្រោះ ខ្ញុំបានពង្រីកក្តីស្រឡាញ់ដ៏ជ្រាលជ្រៅមួយចំពោះអ្នក ដែលជាបងប្អូនស្រ្តីក្នុងសមាគមន៍សង្គ្រោះនៃសាសនាចក្រនេះ ហើយព្រះអម្ចាស់បានពង្រីកនូវចក្ខុវិស័យរបស់ខ្ញុំ ថាទ្រង់មានព្រះទ័យយ៉ាងណាអំពីយើង និងអ្វីដែលទ្រង់រំពឹងពីយើង ។

ខ្ញុំបានដាក់ចំណងជើងសារដំណឹងនេះថា « ឱ ខ្ញុំសង្ឃឹមថា ចៅស្រីទាំងឡាយរបស់ខ្ញុំនឹងយល់អំពីសមាគមន៍សង្គ្រោះ » ។ ពួកចៅស្រីធំៗរបស់ខ្ញុំ កំពុងរវល់ធ្វើសៀវភៅការអភិវឌ្ឍន៍ខ្លួន និងកំពុងអភិវឌ្ឍទម្លាប់ និងលក្ខណៈនៃភាពជាស្រ្តីសុចរិត ។ មិនយូរទេ ពួកគេ និងមិត្តគេនឹងទទួលការខុសត្រូវចំពោះភាពជាបងប្អូនស្រ្តីដ៏អស្ចារ្យដែលមាននៅពាសពេញពិភពលោកនេះ ។

ខ្ញុំសង្ឃឹមថា អ្វីដែលខ្ញុំនិយាយក្នុងសារដំណឹងនេះ នឹងផ្តល់ដល់ពួកគេ រួមទាំងអ្នកទាំងអស់ដែលឮ ឬអានវា នូវការយល់ដឹងដ៏ច្បាស់មួយ ពីអ្វីដែលព្រះអម្ចាស់មានព្រះទ័យ សម្រាប់ពួកបុត្រីទ្រង់ ពេលដែលសមាគមន៍សង្គ្រោះត្រូវបានបង្កើតឡើង ។

**គំរូពីបុរាណមួយនៃភាពជាសិស្ស**

ខ្ញុំសង្ឃឹមថា ពួកចៅស្រីខ្ញុំនឹងយល់ថា សមាគមន៍សង្គ្រោះសព្វថ្ងៃនេះ គឺត្រូវបានបង្កើតឡើងតាមគំរូនៃភាពជាសិស្សដែលមានក្នុងសាសនាចក្រកាលពីបុរាណ ។ ពេលព្រះអង្គសង្គ្រោះបានស្ថាបនាសាសនាចក្រទ្រង់ក្នុងសម័យគម្ពីរសញ្ញាថ្មី « ស្រ្តីគឺជាអ្នកចូលរួមដ៏ចាំបាច់ ក្នុងការបម្រើ [ របស់ទ្រង់ ] » ។[1] ទ្រង់បានអញ្ជើញ ម៉ាថា និងម៉ារា ដែលជាអ្នកដើរតាមដ៏លះបង់ពីរនាក់របស់ទ្រង់ នៅក្នុងផ្ទះម៉ាថា ។ ពេលម៉ាថាបានស្តាប់ និងបម្រើទ្រង់តាមទម្លាប់ក្នុងសម័យគេ នោះទ្រង់បានជួយនាងឲ្យឃើញថា នាងអាចធ្វើបានច្រើនជាងនោះ ។ ទ្រង់បានជួយម៉ាថា និងម៉ារ៉ា ឲ្យយល់ថាពួកគេអាចជ្រើសធ្វើ « ចំណែកយ៉ាងល្អ » នោះ ដែលមិនត្រូវយកចេញពីពួកគេឡើយ ។[2] បន្ទូលដ៏ទន់ភ្លន់នេះ ជាការអញ្ជើញឲ្យចូលរួមក្នុងការបម្រើរបស់ព្រះអម្ចាស់ ។ ហើយក្រោយមកទៀត ក្នុងគម្ពីរសញ្ញាថ្មី ទីបន្ទាល់ដ៏រឹងមាំរបស់ម៉ាថា អំពីទេវភាពនៃព្រះអង្គសង្គ្រោះ បានផ្តល់ដល់យើងនូវការយល់ដឹងដ៏ជ្រាលជ្រៅមួយចំនួន ពីជំនឿ និងភាពជាសិស្សរបស់នាង ។[3]

ពេលយើងអានទៅមុខទៀតក្នុងគម្ពីរសញ្ញាថ្មី យើងរៀនថា ពួកសាវកបានបន្តស្ថាបនាសាសនាចក្រព្រះអម្ចាស់ ។ យើងរៀនផងដែរ អំពីពួកស្រ្តីដ៏ស្មោះត្រង់ ដែលជាគំរូនៃភាពជាសិស្ស បានជួយដល់ការរីកចម្រើននៃសាសនាចក្រ ។ ប៉ុលបាននិយាយពីពួកសិស្សស្រីក្នុងកន្លែង ដូចជា អេភេសូរ[4] និង ភីលីព ។[5] តែពេលដែលសាសនាចក្រពិតរបស់ព្រះអម្ចាស់បានបាត់បង់ដោយការក្បត់សាសនា នោះគំរូនៃភាពជាសិស្សនេះក៏បានបាត់បង់ផងដែរ ។

ពេលព្រះអម្ចាស់ចាប់ផ្តើមស្តារសាសនាចក្រទ្រង់ឡើងវិញតាមរយៈព្យាការី យ៉ូសែប ស៊្មីធ នោះទ្រង់បានបញ្ចូលពួកស្រ្តីក្នុងគំរូមួយនៃភាពជាសិស្សម្តងទៀត ។ ពីរបីខែក្រោយពីសាសនាចក្រត្រូវបានស្ថាបនាឡើងជាផ្លូវការ ព្រះអម្ចាស់បានបើកសម្តែងថា អិមម៉ា ស៊្មីធ ត្រូវញែកចេញជាអ្នកដឹកនាំ និងគ្រូម្នាក់ ក្នុងសាសនាចក្រ ហើយក្នុងនាមជាអ្នកជំនួយផ្លូវការដល់ស្វាមីគាត់ ដែលជាព្យាការី ។[6] ក្នុងការហៅរបស់គាត់ដើម្បីជួយព្រះអម្ចាស់ស្ថាបនានគរទ្រង់ គាត់បានទទួលការណែនាំពីរបៀបពង្រីកជំនឿ និងភាពសុចរិតរបស់គាត់ របៀបពង្រឹងគ្រួសារ និងផ្ទះគាត់ និងរបៀបបម្រើអ្នកដទៃទៀត ។

ខ្ញុំសង្ឃឹមថា ពួកចៅស្រីខ្ញុំនឹងយល់ថា ចាប់ពីថ្ងៃដែលដំណឹងល្អបានចាប់ផ្តើមស្តារឡើងវិញ ក្នុងគ្រាកាន់កាប់ត្រួតត្រានេះ ព្រះអម្ចាស់ត្រូវការពួកស្រ្តីចូលរួមជាសិស្សទ្រង់ ។

ឧទាហរណ៍មួយនៃការបរិច្ចាគដ៏ធំធេញ គឺក្នុងកិច្ចការផ្សព្វផ្សាយ ។ ការរីកចម្រើនដ៏អស្ចារ្យរបស់សាសនាចក្រពីដំបូង កើតឡើងដោយសារពួកបុរសដ៏ស្មោះត្រង់ ដែលសុខចិត្តទុកគ្រួសារគេ ហើយធ្វើដំណើរទៅកន្លែងដែលគេមិនស្គាល់ ហើយបានទ្រាំទ្រនឹងការលំបាក ដើម្បីបង្រៀនដំណឹងល្អ ។ ទោះយ៉ាងណា បុរសទាំងនេះយល់ថា បេសកកម្មរបស់គេនឹងមិនអាចធ្វើបាន ដោយគ្មានជំនឿដ៏ពេញលេញ និងភាពជាដៃគូនៃពួកស្រ្តីនៅក្នុងជីវិតរបស់ពួកគេ ដែលជាអ្នកថែទាំផ្ទះសម្បែងនោះបានឡើយ ។

**ទំនាក់ទំនងជាមួយបព្វជិតភាព**

ខ្ញុំសង្ឃឹមថា ពួកចៅស្រីខ្ញុំនឹងយល់ថា ព្រះអម្ចាស់បានបំផុសដល់ព្យាការី យ៉ូសែប ស៊្មីធ ឲ្យរៀបចំពួកស្ត្រីនៃសាសនាចក្រ « ក្រោមបព្វជិតភាព តាមគំរូនៃបព្វជិតភាព »[7] ហើយដើម្បីបង្រៀនពួកគេពី « របៀបដែល [ ពួកគេ ] នឹងចូលមកទទួលឯកសិទ្ធ ពរជ័យ និងអំណោយទានទាំងឡាយនៃបព្វជិតភាព » ។[8]

ពេលសមាគមន៍សង្គ្រោះត្រូវបានស្ថាបនាជាផ្លូវការ អិមម៉ា ស៊្មីធ បានបន្តការហៅរបស់គាត់ជាអ្នកដឹកនាំម្នាក់ ។ គាត់ត្រូវបានផ្តល់ឈ្មោះជាប្រធាននៃអង្គការនោះ ដោយមានទីប្រឹក្សាពីរនាក់ បម្រើជាមួយគាត់ក្នុងគណៈប្រធានមួយ ។ លើសពីការជ្រើសដោយសម្លេងឆ្នោតច្រើន ដូចជាការធម្មតាក្នុងអង្គការខាងក្រៅសាសនាចក្រនោះ គណៈប្រធាននេះត្រូវបានហៅដោយវិវរណៈ គាំទ្រដោយអ្នកទាំងឡាយដែលពួកគេនឹងបម្រើ ហើយញែកចេញដោយអ្នកដឹកនាំបព្វជិតភាព ដើម្បីបម្រើក្នុងការហៅរបស់ពួកគេ ហេតុនោះហើយ ការត្រូវបាន « ហៅពីព្រះ ដោយការព្យាករណ៍ និងដោយការដាក់ដៃលើ ដោយអស់អ្នកណាដែលមានសិទ្ធិអំណាច » ។[9]

ដោយត្រូវបានរៀបចំឡើងក្រោមបព្វជិតភាព នោះបានធ្វើឲ្យគណៈប្រធានអាចទទួលការណែនាំពីព្រះអម្ចាស់ និងព្យាការីទ្រង់ សម្រាប់កិច្ចការដាក់លាក់ណាមួយ ។ ហើយអង្គការនៃសមាគមន៍សង្គ្រោះ បានធ្វើឲ្យឃ្លាំងព្រះអម្ចាស់ពេញដោយ ទេពកោសល្យ ពេលវេលា និងធនធានទាំងឡាយ ដើម្បីយកទៅបម្រើក្នុងប្រាជ្ញា និងរបៀបរៀបរយ ។

ក្រុមស្ត្រីដំបូងនោះ បានយល់ថា ពួកគេត្រូវបានផ្តល់នូវសិទ្ធិអំណាចដើម្បីបង្រៀន បំផុស និងរៀបចំបងប្អូនស្ត្រីជាសិស្ស ដើម្បីជួយក្នុងកិច្ចការនៃក្តីសង្គ្រោះរបស់ព្រះអម្ចាស់ ។ ក្នុងការប្រជុំលើកទីមួយរបស់គេ បងប្អូនស្ត្រីត្រូវបានបង្រៀនពីគោលបំណងនៃសមាគមន៍សង្គ្រោះ---ដើម្បីពង្រីកជំនឿ និងសុចរិតភាពផ្ទាល់ខ្លួន ពង្រឹងគ្រួសារ និងផ្ទះ និងស្វែងរក និងជួយដល់ពួកអ្នកដែលត្រូវការជំនួយ ។

ខ្ញុំសង្ឃឹមថា ពួកចៅស្រីខ្ញុំនឹងយល់ថា អង្គការសមាគមន៍សង្គ្រោះ គឺជាផ្នែកដ៏ចាំបាច់នៃការរៀបចំពួកបរិសុទ្ធដើម្បីទទួលឯកសិទ្ធិ ពរជ័យ និងអំណោយទានទាំងឡាយ ដែលមានតែនៅក្នុងព្រះវិហារបរិសុទ្ធ ។ ប្រធាន យ៉ូសែប  ហ្វីលឌីង ស៊្មីធ បានបង្រៀនថា សមាគមន៍សង្គ្រោះ « ជាផ្នែកមួយដ៏ចាំបាច់នៃនគរព្រះនៅលើផែនដី » ហើយ « ត្រូវបានរៀបចំ និងដំណើរការតាមបែបនោះ ដើម្បីជួយដល់សមាជិកស្មោះត្រង់របស់អង្គការនោះឲ្យទទួលបានជីវិតដ៏អស់កល្បក្នុងនគរព្រះវរបិតា » ។[10]

យើងអាចស្រមៃថាវាយ៉ាងណា សម្រាប់បងប្អូនស្ត្រី ក្នុងការប្រជុំលើកដំបូងទាំងនោះរបស់ពួកគេ នៅក្នុងឃ្លាំងធ្វើពីឥដ្ឋពណ៌ក្រហមរបស់ យ៉ូសែប ស៊្មីធ ដែលនៅទល់មុខនឹងទីទួលដែលកំពុងសង់ព្រះវិហារបរិសុទ្ធនៅលើនោះ ខណៈដែលព្យាការីបានបង្រៀនពួកគេថា « គួរតែមានសមាគមន៍ដ៏ពិសេសមួយ ដែលញែកចេញពីអស់ទាំងការណ៍អាក្រក់នៃលោកិយ ដែលជាជម្រើស ប្រកបដោយគុណធម៌ និងបរិសុទ្ធ » ។[11]

ខ្ញុំសង្ឃឹមថា ពួកចៅស្រីខ្ញុំឲ្យតម្លៃព្រះវិហារបរិសុទ្ធ ដូចជាបងប្អូនស្ត្រីនៃសមាគមន៍សង្គ្រោះដំបូងនោះ ដែលបានជឿថា ពរជ័យព្រះវិហារបរិសុទ្ធជារង្វាន់ដ៏មហិមា និងជាគោលដៅដ៏ធំនៃស្ត្រីពួកបរិសុទ្ធគ្រប់រូប ។ ដូចជាបងប្អូនស្ត្រីនៃសមាគមន៍សង្គ្រោះដំបូងនោះដែរ ខ្ញុំសង្ឃឹមថា ពួកចៅស្រីខ្ញុំនឹងពុះពាររាល់ថ្ងៃ ដើម្បីឲ្យមានភាពចាស់ទុំគ្រប់គ្រាន់ ដើម្បីធ្វើ និងរក្សាសេចក្តីសញ្ញាដ៏ពិសិដ្ឋក្នុងព្រះវិហារបរិសុទ្ធ ហើយថា ពេលពួកគេទៅព្រះវិហារបរិសុទ្ធ ពួកគេនឹងយកចិត្តទុកដាក់លើអ្វីទាំងអស់ដែលត្រូវបាននិយាយ និងធ្វើ ។ តាមរយៈពរជ័យនៃព្រះវិហារបរិសុទ្ធ ពួកគេនឹងត្រូវបានប្រដាប់ដោយអំណាច[12] និងពរជ័យដើម្បីទទួល « កូនសោរនៃចំណេះវិជ្ជាពីព្រះ » ។[13] តាមរយៈពិធីការនៃបព្វជិតភាព ដែលមានក្នុងព្រះវិហារបរិសុទ្ធ ពួកគេនឹងទទួលពរជ័យដើម្បីបំពេញទំនួលខុសត្រូវដ៏ទេវភាព និងអស់កល្បរបស់ពួកគេ ហើយពួកគេនឹងសន្យា ដើម្បីរស់នៅក្នុងនាមជាសិស្សដែលពេញដោយការតាំងចិត្ត ។ ខ្ញុំមានអំណរគុណដែល គោលបំណងចម្បងមួយរបស់ព្រះអម្ចាស់ ក្នុងការបង្កើតសមាគមន៍សង្គ្រោះ គឺដើម្បីផ្តល់ទំនួលខុសត្រូវដល់ស្ត្រី ដើម្បីជួយគ្នាទៅវិញទៅមករៀបចំ « សម្រាប់ពរជ័យនៃបព្វជិតភាពដែលកាន់តែធំជាង ដែលមានក្នុងពិធីការ និងសេចក្តីសញ្ញានៃព្រះវិហារបរិសុទ្ធ » ។[14]

**ទីជម្រក និងឥទ្ធិពលនៃភាពជាបងប្អូនស្រីនៅពាសពេញពិភពលោក**

ខ្ញុំសង្ឃឹមថា ពួកចៅស្រីខ្ញុំនឹងយល់ពីឥទ្ធិពល និងសមត្ថភាពដ៏សំខាន់នៃភាពជាបងប្អូនស្រីដ៏អស្ចារ្យនៅពាសពេញពិភពលោកនៃសមាគមន៍សង្គ្រោះ ។ តាំងពីឆ្នាំ 1842 សាសនាចក្របានផ្សព្វផ្សាយឆ្ងាយហួសពីទីក្រុង ណៅវូ ហើយឥឡូវនេះ សមាគមន៍សង្គ្រោះមាននៅជាង 170 ប្រទេស

ដែលបងប្អូនស្រីនិយាយជាង 80 ភាសា ។ ជារៀងរាល់សប្តាហ៍ វួដ និងសាខាថ្មី ត្រូវបានរៀបចំឡើង ហើយសមាគមន៍សង្គ្រោះថ្មីៗ ក្លាយជាផ្នែកនៃបងប្អូនស្ត្រីដ៏រីកលូតលាស់ដែល « លាតសន្ធឹងកាត់ទ្វីបទាំងឡាយ » ។[15] ពេលសមាគមន៍សង្គ្រោះនៅតូច ហើយបានត្រូវបង្កើតឡើងជាចម្បងតែក្នុងរដ្ឋយូថាហ៍ នោះ អ្នកដឹកនាំអាចផ្តោតទៅលើអង្គការ និងភាពជាសិស្សរបស់ពួកគេបានច្រើន លើកម្មវិធីសង្គមក្នុងមូលដ្ឋាន និងការងារសង្គ្រោះដែលទាក់ទងគ្នាទៅវិញទៅមក ។ ពួកគេបានបង្កើតឧស្សាហកម្មផ្ទះ និងដាក់ចេញនូវគម្រោងកសាងមន្ទីរពេទ្យ និងឃ្លាំងធញ្ញជាតិ ។ កិច្ចប្រឹងប្រែងរបស់សមាគមសង្គ្រោះដំបូងៗ បានជួយបង្កើតគំរូនៃភាពជាសិស្ស ដែលឥឡូវនេះត្រូវបានអនុវត្តនៅពាសពេញផែនដី ។ កាលដែលសាសនាចក្ររីកចម្រើន នោះសមាគមសង្គ្រោះអាចមានលទ្ធភាពបំពេញគោលបំណងរបស់អង្គការ ក្នុងគ្រប់វួដ និងសាខា ក្នុងគ្រប់ស្តេក និងមណ្ឌល ខណៈដែលសម្របតាមពិភពលោកដ៏ផ្លាស់ប្តូរនេះ ។

រាល់ថ្ងៃ បងប្អូនស្ត្រីនៃសមាគមន៍សង្គ្រោះជុំវិញពិភពលោក ជួបឧបសគ្គ និងបទពិសោធន៍នៃជីវិតមែងស្លាប់គ្រប់យ៉ាង ។ សព្វថ្ងៃនេះ ស្ត្រី និងគ្រួសារគេប្រឈមដោយផ្ទាល់នឹងការរំពឹងដែលមិនបានដឹងជាមុន ជំងឺខាងផ្លូវចិត្ត ខាងរូបកាយ និងខាងវិញ្ញាណ គ្រោះថ្នាក់ និងការស្លាប់ ។ បងប្អូនស្ត្រីខ្លះរងទុក្ខដោយភាពឯកោ និងការខកចិត្ត ដោយព្រោះគេពុំមានគ្រួសារផ្ទាល់ខ្លួន ហើយអ្នកខ្លះទៀតរងទុក្ខ ដោយសារលទ្ធផលនៃការជ្រើសខុសដោយសមាជិកគ្រួសារ ។ ខ្លះជួបសង្គ្រាម ឬការអត់ឃ្លាន ឬគ្រោះធម្មជាតិ និងខ្លះទៀតកំពុងរៀនពីសម្ពាធនៃការញៀន ការអត់ការងារធ្វើ ឬការអប់រំ និងការបំពាក់បំប៉នមិនគ្រប់គ្រាន់ ។ ការលំបាកទាំងអស់នេះនឹងអាចឈានទៅការបំផ្លាញក្តីជំនឿ និងធ្វើឲ្យបុគ្គលម្នាក់ៗ និងគ្រួសារអស់កម្លាំង ។ គោលបំណងមួយរបស់ព្រះអម្ចាស់ក្នុងការរៀបចំបងប្អូនស្ត្រីក្នុងភាពជាសិស្ស គឺដើម្បីផ្តល់ការសង្គ្រោះ ដែលនឹងលើកពួកគេឡើងខ្ពស់ជាង « អ្វីទាំងអស់ដែលរារាំងក្តីអំណរ និងការរីកចម្រើនរបស់ស្ត្រី » ។[16] ក្នុងគ្រប់វួដ និងសាខា មានសមាគមន៍ សង្គ្រោះមួយ ដោយមានបងប្អូនស្ត្រីដែលអាចស្វែងរក និងទទួលវិវរណៈ និងការប្រឹក្សាពីអ្នកដឹកនាំបព្វជិតភាព ដើម្បីពង្រឹងគ្នាទៅវិញទៅមក និងរកដំណោះស្រាយទាំងឡាយ ដែលអាចអនុវត្តក្នុងផ្ទះ និងសហគមគេផ្ទាល់ ។

ខ្ញុំសង្ឃឹមថា ពួកចៅស្រីខ្ញុំនឹងយល់ថា តាមរយៈសមាគមន៍សង្គ្រោះ ភាពជាសិស្សរបស់ពួកគេនឹងត្រូវបានពង្រីក ហើយពួកគេអាចចូលរួមជាមួយអ្នកផ្សេងទៀត ក្នុងកិច្ចការដែលព្រះអង្គសង្គ្រោះបានធ្វើ ។ តាមរយៈការបម្រើនេះ ពួកគេអាចធ្វើឲ្យពិភពលោកមានការផ្លាស់ប្តូរ ។ បើកំណត់ត្រាជាក់លាក់មួយត្រូវបានរក្សាពីគ្រប់ការបម្រើ និងជំនួយទាំងអស់ ដែលបានផ្តល់ដោយសមាគមន៍ សង្គ្រោះ តាំងពីសមាគមន៍ត្រូវបានបង្កើតឡើង នោះវានឹងជាកំណត់ត្រាមួយដ៏អស្ចារ្យ និងជាប្រវត្តិសាស្ត្រ ។

ពួកចៅស្រីខ្ញុំ គប្បីដឹងផងដែរថា ភាពបងប្អូនស្ត្រីនៃសមាគមន៍សង្គ្រោះ អាចផ្តល់កន្លែងសុវត្ថិភាព ជម្រក និងការការពារមួយ ។[17] ខណៈដែលជំនាន់របស់យើងកាន់តែពិបាក នោះបងប្អូនស្ត្រីដ៏ស្មោះត្រង់នៃសមាគមន៍សង្គ្រោះ នឹងជួយការពារផ្ទះរបស់ក្រុងស៊ីយ៉ូន ពីសម្លេងដ៏ខ្លាំងនៃលោកិយ និងពីឥទ្ធិពលដ៏រំខាន និងអន្តរាយរបស់សាតាំង ។ ហើយតាមរយៈសមាគមន៍សង្គ្រោះ ឥទ្ធិពលនៃស្ត្រីសុចរិតទាំងឡាយ អាចផ្តល់ពរដល់កូនចៅព្រះវរបិតាជាច្រើនថែមទៀត ។

**ភាពជាសិស្សនៃការបម្រើ និងការខ្វល់ខ្វាយដ៏យកចិត្តទុកដាក់**

ខ្ញុំសង្ឃឹមថា ពួកចៅស្រីខ្ញុំនឹងយល់ថា ការបង្រៀនសួរសុខទុក្ខ ជាការបង្ហាញភាពជាសិស្សរបស់គេ និងជារបៀបត្រឹមត្រូវមួយ ដើម្បីគោរពដល់សេចក្តីសញ្ញារបស់គេ ។ កត្តានៃភាពជាសិស្សរបស់យើងនេះ អាចស្រដៀងគ្នាយ៉ាងខ្លាំងទៅនឹងការបម្រើរបស់ព្រះអង្គសង្គ្រោះយើង ។ គ្រាដំបូងៗរបស់សមាគមន៍សង្គ្រោះ គណៈកម្មការសួរសុខទុក្ខមួយ ពីវួដនីមួយៗបានទទួលការចាត់តាំងឲ្យធ្វើការប៉ាន់ប្រមាណតម្រូវការ និងប្រមូលវិភាគទានដើម្បីចែកចាយដល់ពួកអ្នកដែលត្រូវការជំនួយ ។ អស់រយៈពេលជាច្រើនឆ្នាំ បងប្អូនស្ត្រី និងអ្នកដឹកនាំនៃសមាគមន៍សង្គ្រោះបានរៀនមួយជំហានម្តងៗ និងបានអភិវឌ្ឍសមត្ថភាពរបស់គេក្នុងការថែរក្សាអ្នកដទៃទៀត ។ មានពេលជាច្រើន ដែលបងប្អូនស្ត្រីបានផ្តោតលើការសួរសុខទុក្ខ បង្រៀនមេរៀន និងផ្ញើសារតាមទ្វាររបស់បងប្អូនស្ត្រីរបស់គេ ពេលពួកគេមិននៅ ។ ការអនុវត្តន៍ទាំងនេះ បានជួយបងប្អូនស្ត្រីរៀនពីគំរូនៃការខ្វល់ខ្វាយដ៏យកចិត្តទុកដាក់ ។ គឺដូចជាមនុស្សនៅជំនាន់ម៉ូសេ ដែលបានផ្តោតលើការរក្សាបញ្ជីដ៏វែងនៃច្បាប់ទាំងឡាយ នោះបងប្អូនស្ត្រីនៃសមាគមន៍សង្គ្រោះ មានពេលខ្លះ បានរំពឹងថានឹងដាក់ទាំងច្បាប់ជាសំណេរ និងមិនមែនជាសំណេរ ក្នុងបំណងដើម្បីយល់ពីរបៀបដើម្បីពង្រឹងគ្នាទៅវិញទៅមក ។

ដោយមានតម្រូវការនៃការរំដោះ និងការសង្គ្រោះ ជាខ្លាំង ក្នុងជីវិតបងប្អូនស្ត្រី និងសមាជិកគ្រួសាររបស់ពួកគេនៅសព្វថ្ងៃនេះ នោះព្រះវរបិតាសួគ៌យើងត្រូវការយើង ដើម្បីដើរតាមផ្លូវដែលខ្ពស់ជាង និងដែលបង្ហាញពីភាពជាសិស្សរបស់យើង ដោយការខ្វល់ខ្វាយដោយស្មោះត្រង់ ចំពោះកូនចៅទ្រង់ ។ ដោយចងចាំគោលបំណងដ៏សំខាន់នេះនៅក្នុងចិត្ត នោះអ្នកដឹកនាំត្រូវបានបង្រៀនឲ្យស្នើសុំនូវរបាយការណ៍ អំពីសុខមាលភាពខាងវិញ្ញាណ និងខាង

សាច់ឈាមរបស់បងប្អូនស្ត្រី និងគ្រួសារគេ និងអំពីការបម្រើដែលបានផ្ដល់ ។[18] ហើយគ្រូសួរសុខទុក្ខមានទំនួលខុសត្រូវដើម្បី « រៀនស្គាល់ និងស្រឡាញ់ដល់បងប្អូនស្ត្រីម្នាក់ៗដោយស្មោះស្ម័គ្រ ដើម្បីជួយពង្រឹងដល់សេចក្ដីជំនឿរបស់គាត់ ហើយផ្ដល់ការបម្រើ » ។[19]

ព្រោះយើងតាំងចិត្តជាសិស្សនៃព្រះអង្គសង្គ្រោះ នោះយើងកំពុងអភិវឌ្ឍសមត្ថភាពយើង ដើម្បីធ្វើការណ៍ដែលទ្រង់នឹងធ្វើ បើទ្រង់គង់នៅទីនេះ ។ យើងដឹងថា ចំពោះទ្រង់ គឺការខ្វល់ខ្វាយរបស់យើងដែលសំខាន់ ដូច្នេះយើងកំពុងព្យាយាមផ្ដោតលើការខ្វល់ខ្វាយចំពោះបងប្អូនស្ត្រីរបស់យើង ជាជាងការបញ្ចប់បញ្ជីនៃកិច្ចការដែលត្រូវធ្វើ ។ ការបម្រើដ៏ពិតគឺត្រូវបានវាស់វែង ដោយជម្រៅនៃក្ដីសប្បុរសរបស់យើង ជាជាងដោយភាពឥតខ្ចោះនៃស្ថិតិរបស់យើង ។ យើងនឹងដឹងថា យើងជោគជ័យក្នុងការបម្រើរបស់យើង ក្នុងនាមជាគ្រូសួរសុខទុក្ខ នៅពេលបងប្អូនស្ត្រីយើងអាចនិយាយថា « គ្រូសួរសុខទុក្ខខ្ញុំជួយខ្ញុំឲ្យរីកចម្រើនខាងវិញ្ញាណ » និងថា « ខ្ញុំដឹងថា គ្រូសួរសុខទុក្ខខ្ញុំខ្វល់ខ្វាយយ៉ាងជ្រាលជ្រៅចំពោះខ្ញុំ និងគ្រួសារខ្ញុំ » និងថា « បើខ្ញុំមានបញ្ហា ខ្ញុំដឹងថា គ្រូសួរសុខទុក្ខខ្ញុំនឹងធ្វើអ្វីមួយ ដោយមិនចាំបាច់ខ្ញុំសុំគាត់នោះទេ » ។ បងប្អូនស្ត្រី និងអ្នកដឹកនាំដែលយល់ពីសារៈសំខាន់នៃការបម្រើអ្នកដទៃនឹងប្រឹក្សាជាមួយគ្នា ដើម្បីស្វែងរក និងទទួលវិវរណៈ ពីរបៀបដើម្បីបំភ្លឺដល់គ្រូសួរសុខទុក្ខ និងពីរបៀបដើម្បីរៀបចំ និងអនុវត្តការបម្រើរបស់ពួកគេ ។

ជាងនោះទៀត ការបង្រៀនសួរសុខទុក្ខ ជាការពង្រីកនូវទំនួលខុសត្រូវរបស់ប៊ីស្សព ក្នុងការខ្វល់ខ្វាយពីហ្វូងចៀមនៃព្រះ ។ ប៊ីស្សព និងប្រធានសមាគមសង្គ្រោះ ត្រូវការការបម្រើរបស់គ្រូសួរសុខទុក្ខដែលប្រកបដោយការបំផុស ដើម្បីជួយពួកគាត់ក្នុងការបំពេញទំនួលខុសត្រូវរបស់ពួកគាត់ ។ តាមរយៈការបម្រើរបស់គ្រូសួរសុខទុក្ខ ប្រធានសមាគមសង្គ្រោះ អាចដឹងពីសុខមាលភាពរបស់បងប្អូនស្ត្រីម្នាក់ៗក្នុងវួដ ហើយរាយការណ៍ពីសុខមាលភាពគេ ពេលគាត់ជួបជាមួយប៊ីស្សពគាត់ ។

ប្រធាន ថូម៉ាស អេស ម៉នសុន បានបង្រៀនយើងថា « ពេលយើងពុះពារដោយចិត្តជឿ ឥតសង្ស័យអ្វីសោះ ដើម្បីបំពេញតួនាទីដែលបានចាត់តាំងដល់យើង ពេលយើងស្វែងរកការបំផុសពីព្រះដ៏មានមហិទ្ធិឫទ្ធិ ក្នុងការបំពេញទំនួលខុសត្រូវរបស់យើង នោះយើងអាចទទួលលទ្ធផលដូចជាអព្ភូតហេតុ » ។[20] ខ្ញុំសង្ឃឹមថា ពួកចៅស្រីខ្ញុំនឹងចូលរួមក្នុងអព្ភូតហេតុទាំងឡាយ កាលដែលពួកគេជួយឲ្យការបង្រៀនសួរសុខទុក្ខក្លាយជាគំរូមួយនៃភាពជាសិស្ស ដែលព្រះអម្ចាស់នឹងទទួលស្គាល់ ពេលទ្រង់យាងមកម្ដងទៀត ។

**ការបំពេញគោលបំណងរបស់សមាគមន៍សង្គ្រោះ**

ឥឡូវនេះ ការបង្រៀនដ៏ចាំបាច់ទាំងនេះ និងផ្សេងៗទៀត អំពីសមាគមន៍សង្គ្រោះមានសម្រាប់ពួកចៅស្រីខ្ញុំ ដើម្បីសិក្សា គឺនៅក្នុងសៀវភៅ *Daughters in My Kingdom: The History and Work of Relief Society* ។ សៀវភៅនេះមានកំណត់ត្រាមួយ អំពីកេរដំណែលនៃសមាគមន៍សង្គ្រោះ និងពួកស្ត្រីនៃសាសនាចក្រនេះ ។ វានឹងបង្រួបបង្រួម និងតម្រែតម្រង់ភាពជាបងប្អូនស្ត្រីពាសពេញពិភពលោកចូលជាផ្លូវតែមួយ ជាមួយនឹងគោលបំណងនៃសមាគមន៍សង្គ្រោះ និងគំរូ និងឯកសិទ្ធិ ក្នុងនាមជាសិស្សនៃព្រះគ្រីស្ទ ។ វាជាទីបន្ទាល់ពីសារៈសំខាន់នៃតួនាទីរបស់ស្ត្រី ក្នុងផែនការសុភមង្គលរបស់ព្រះវរបិតា ហើយវាផ្ដល់នូវបទដ្ឋានដ៏រឹងមាំមួយនៃអ្វីដែលយើងជឿ អ្វីដែលយើងធ្វើ និងអ្វីដែលយើងការពារ ។ គណៈប្រធានទីមួយបានលើកទឹកចិត្តយើងឲ្យ « សិក្សាសៀវភៅនេះ ហើយសូមឲ្យសេចក្ដីពិតដ៏អស់កល្ប និងគំរូដ៏បំផុសរបស់វា ជះឥទ្ធិពលក្នុងជីវិត [ យើង ] ចុះ » ។[21]

ដោយការដឹងថា អង្គការនៃសមាគមន៍សង្គ្រោះត្រូវបានបង្កើតឡើងដោយទេវភាព នោះប្រធាន យ៉ូសែប  អេហ្វ ស្ម៊ីធ បានប្រាប់ដល់បងប្អូនស្ត្រីនៃសមាគមន៍សង្គ្រោះថា ៖ « វាជាទំនួលខុសត្រូវរបស់អ្នក ដើម្បីដឹកនាំពិភពលោកនេះ និងជាពិសេស ដើម្បីដឹកនាំស្ត្រីនៃពិភពលោកនេះ... ។ អ្នកគឺជាក្បាល...មិនមែនជាកន្ទុយទេ » ។ ដោយពេលវេលានៃការយាងត្រឡប់មករបស់ព្រះអម្ចាស់កាន់តែខិតជិត នោះខ្ញុំសង្ឃឹមថា ពួកចៅស្រីខ្ញុំ នឹងកាន់តែរឹងមាំ នឹងក្លាយជាស្ត្រីស្មោះត្រង់ ដែលអនុវត្តគោលការណ៍ និងគំរូនៃសមាគមន៍សង្គ្រោះ ក្នុងជីវិតរបស់គេ ។ ពេលសមាគមន៍សង្គ្រោះក្លាយជាមធ្យោបាយមួយក្នុងជីវិតពួកគេ ពួកគេនឹងបម្រើដោយភាពសាមគ្គី ជាមួយអ្នកឯទៀត ដើម្បីបំពេញគោលបំណងដ៏ពិសិដ្ឋរបស់សមាគមន៍ ។ ខ្ញុំមានទីបន្ទាល់ពីសាសនាចក្ររបស់ព្រះយេស៊ូវគ្រីស្ទដែលបានស្ដារឡើងវិញ ហើយខ្ញុំមានអំណរគុណសម្រាប់គំរូនៃភាពជាសិស្ស ដែលត្រូវបានស្ដារ ពេលដែលព្រះអម្ចាស់បានបំផុសដល់ព្យាការី យ៉ូសែប ស្ម៊ីធ ឲ្យរៀបចំសមាគមន៍សង្គ្រោះឡើង ។ ក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន ។

កំណត់ចំណាំ

1. *Daughters in My Kingdom: The History and Work of Relief Society* (2011) ទំព័រ 3 ។
2. សូមមើល លូកា 10:38--42 ។
3. សូមមើល យ៉ូហាន 11:20--27 ។
4. សូមមើល កិច្ចការ 18:24--26; រ៉ូម 16:3--5 ។

5. សូមមើល ភីលីព 4:1--4 ។

6. សូមមើល គោលលទ្ធិ និងសេចក្ដីសញ្ញា 25:1--9 ។

7. Joseph Smith, in *Daughters in My Kingdom,* ទំព័រ 12 ។

8. Joseph Smith, in *History of the Church,* 4:602 ។

9. មាត្រានៃសេចក្ដីជំនឿ 1:5 ។

10. Joseph Fielding Smith ក្នុង *Daughters in My Kingdom* ទំព័រ 97 ។

11. Joseph Smith, in *Daughters in My Kingdom,* ទំព័រ 15 ។

12. សូមមើល គោលលទ្ធិ និងសេចក្ដីសញ្ញា 109:22, សូមមើលផងដែរ Sheri L. Dew ក្នុង *Daughters in My Kingdom* ទំព័រ 128 ។

13. គោលលទ្ធិ និងសេចក្ដីសញ្ញា 84:19, សូមមើលផងដែរ Ezra Taft Benson ក្នុង *Daughters in My Kingdom* ទំព័រ 129 ។

14. *Daughters in My Kingdom* ទំព័រ 131 ។

15. Boyd K. Packer ក្នុង *Daughters in My Kingdom* ទំព័រ 99 ។

16. John A. Widtsoe ក្នុង *Daughters in My Kingdom* ទំព័រ 25 ។

17. សូមមើល *Daughters in My Kingdom* ទំព័រ 87 ។

18. សូមមើលក្បួនខ្នាតភាគ 2 ៖ ការគ្រប់គ្រងសាសនាចក្រ (2010)ចំនុច 9.5.4 ។

19. ក្បួនខ្នាតភាគ 2 ចំនុច 9.5.1 ។

20. Thomas S. Monson ក្នុង *Daughters in My Kingdom* ទំព័រ 91 ។

21. First Presidency ក្នុង *Daughters in My Kingdom* ទំព័រ ix ។

22. Joseph F. Smith ក្នុង *Daughters in My Kingdom* ទំព័រ 66 ។